សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៤៦៦ / ១៧.៨.២០០៩
សាលដីកា
១៥ ក្រ.III.ស / ២២.១០.២០១៤

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤ ដោយមានសមាសភាពដូចតទៅ:

<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក ប៉ាន់ គឹមលាន

<u>ក្រឡាបញ្ជី</u>

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងទាស់ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៤៦៦ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ រវាង ៖

ជនជាប់ចោទឈ្មោះ [redacted] រឿន ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីលំនៅកំណើត និងទីលំនៅមុនចាប់ខ្លួន [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] (លែងលះ) មានកូន០១នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៧, ឃុំខ្លួនថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៨។

មានលោក [redacted] ម៉ាច ជាមេធាវីការពារ។

<u>ជាប់ចោទពីបទ:</u> រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅ ភូមិព្រែកតាមេម ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី ០៤, ០៥, ០៦ ខែកុម្ភៈ ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] (ត្រូវជាឪពុកម្តាយជនរងគ្រោះ)។

ជនរងគ្រោះឈ្មោះ [redacted] ស្រីលៀប ភេទស្រី អាយុ១៥ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted]។

## ៦ដំណើររឿងមានដូចតទៅ៖

កាលពីថ្ងៃទីនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៧ វេលាម៉ោង១យប់ ឈ្មោះ [redacted] រឿន បានលួចឡើងផ្ទះជនរងគ្រោះឈ្មោះ [redacted] ស្រីលៀប ហើយចាប់រំលោភ និងសំឡុតគំរាមសម្លាប់ចោល ហើយចាប់រំលោភបានសម្រេច រួចហើយលួចចុះតាមទ្វារក្រោយវិញ។ នៅយប់ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៧ ឈ្មោះ [redacted] រឿន បានលួចឡើងផ្ទះជនរងគ្រោះឈ្មោះ [redacted] ស្រីលៀប ទៀត ហើយធ្វើដូចយប់ថ្ងៃទី១ ដោយបានសម្រេចទៀត។ នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៧ ឈ្មោះ [redacted] រឿន បានលួចឡើងផ្ទះដដែលប្រុងចាប់រំលោភលើឈ្មោះ [redacted] ស្រីលៀប ទៀត តែត្រូវឪពុកម្តាយជនរងគ្រោះដឹងទាន់ ហើយចាប់យកទៅឲ្យមេឃុំហើយបញ្ជូនទៅប៉ុស្តិ៍នគរបាលដោយពុំជួប ក៏ប្រគល់ទៅឲ្យឪពុកឈ្មោះ [redacted] រឿន វិញ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៣ «ឌ» ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១. ផ្តន្ទាទោសលើឈ្មោះ [redacted] រឿន ភេទប្រុស អាយុ៣៣ឆ្នាំ ដាក់ពន្ធនាគារកំណត់១២ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៧ ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅ ភូមិព្រែកតាមេម ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី ០៤, ០៥, ០៦ ខែកុម្ភៈ ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២. បង្គាប់ឲ្យឈ្មោះ [redacted] រឿន សងជម្ងឺចិត្តចំនួន ៦.០០០.០០០រ (ប្រាំមួយលានរៀល) ឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សំណើលើសពីនេះបដិសេធចោល។

៣. សាលក្រមនេះ ជំនុំជម្រះជាសំងាត់ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ចំពោះមុខជនរងគ្រោះ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ចំពោះមុខមេធាវីការពារជនជាប់ចោទ ចំពោះមុខមេធាវីការពារជនរងគ្រោះ។ បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣៦ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ជាជនជាប់ចោទ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៣ «ឌ» ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០០៩ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ០៧ «ក្រ.III.ស» ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៦ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] រឿន ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។ ♻

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៣ «ឧ» ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០០៩ របស់សាលាដំបូងខេត្តកណ្ដាល ទុកជាបានការពេញទាំងមូល។

៣- បង្គាប់ឲ្យបន្តការឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១១ ប្រកាសជាធារណៈ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ, បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

បានឃើញបណ្ដឹងទាស់លេខ ០៦ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] រឿន ជាជនជាប់ចោទ សុំប្ដឹងនឹងសាលដីកាព្រហ្មទណ្ឌលេខ ០៧ «ក្រ.III.ស» ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ ២០១១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ជនជាប់ចោទឈ្មោះ [redacted] រឿន ឆ្លើយថា ខ្លួនពិតជាបាន ឡើងទៅលើផ្ទះជនរងគ្រោះ នៅក្នុងវេលាយប់ថ្ងៃទី០៤, ០៥, ០៦ ខែកុម្ភៈ ឆ្នាំ២០០៧ មែន ប៉ុន្តែនៅយប់ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៧ មិនបានសម្រេចទេ ដោយឪពុកជនរងគ្រោះទៅទាន់ ហើយចាប់ខ្លួនយកទៅប្រគល់ឲ្យអាជ្ញាធរឃុំតែមិនជួប ក៏យកខ្លួនទៅប្រគល់ឲ្យឪពុកម្ដាយខ្លួន។ ខ្លួនទៅរួមភេទនេះ គឺដោយសារមានការព្រមព្រៀងរវាងខ្លួន និងជនរងគ្រោះឈ្មោះ [redacted] ស្រីលៀប និងបាន ហៅឲ្យខ្លួនទៅ ទើបមិនស្រែក។ សំណូមពរសុំបន្ធូរបន្ថយទោសដល់រូបខ្លួន

ក្រឡាបញ្ជី អានចម្លើយជនរងគ្រោះឈ្មោះ [redacted] ស្រីលៀប បានឆ្លើយនៅសាលាដំបូងខេត្តកណ្ដាល។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] អៀ ឆ្លើយថា សុំតុលាការសម្រេចតាមច្បាប់ ខ្លួនមិនបានប្ដឹងឧទ្ធរណ៍ទេ។

## សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ជនជាប់ចោទបានអះអាងថា មានករណីព្រមព្រៀង ប៉ុន្តែទោះបីជាព្រមព្រៀងហើយក៏ដោយ ជនរងគ្រោះជាអនីតិជនអាយុ១៤ឆ្នាំ៩ខែ គឺជនជាប់ចោទត្រូវតែមានទោស ដូច្នេះឃើញថា មានភស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់ របស់តំណាងអយ្យការពិតប្រាកដមែន ដូចនេះតំណាងអយ្យការ សុំតម្កល់សាលក្រមទុកជាបានការ។

## សេចក្ដីសន្និដ្ឋានរបស់មេធាវី

ដំណើររឿងនេះឃើញថា នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៧ កូនក្ដីខ្លួន និងនាង ជាំ ស្រីលៀប

បានណាត់គ្នា ក្នុងការឲ្យកូនក្តីខ្លួនឡើងទៅលើផ្ទះគាត់នៅពេលយប់។ តាមចម្លើយរបស់ជនរងគ្រោះ ក៏បានឆ្លើយនៅដំណាក់កាលសមត្ថកិច្ច ក៏ដូចជានៅចៅក្រមស៊ើបសួរថា នៅពេលល្ងាចម៉ោង១៨ និង ០០នាទី កូនក្តីខ្លួនគឺគាត់បានប្រាប់ថា នៅយប់នេះឡើងទៅផ្ទះមែន ហើយជនរងគ្រោះក៏បានឆ្លើយថា មានការជជែកគ្នាអំពីថា ឡើងទៅផ្ទះយប់នឹងមែន នេះជាចម្លើយរបស់ជនរងគ្រោះ។ ដូចនេះឃើញថា ប្រសិនបើកូនក្តីខ្លួនមានចេតនាប្រព្រឹត្តបទរំលោភសេពសន្ថវៈមែន យប់ទី១ គាត់ឡើងទៅ ចុះយប់ទី២ ទី៣ ម៉េចក៏មិនប្តឹងប្រាប់ឪពុកម្តាយឬដាក់គន្លឹះទ្វារទៅ នេះជាការមួយបង្ហាញឲ្យឃើញថាមានការត្រូវរ៉ូវ គ្នា, ជាធម្មតាផ្ទះតែងតែមានសោរ បើសិនអត់សោរក៏មានគន្លឹះដែរមិនដែលអត់មានទេក្នុងផ្ទះមួយៗ អញ្ចឹងផ្ទះ ត្រូវតែមានគន្លឹះ អញ្ចឹងកូនក្តីខ្លួនចេញចូលបានដោយស្រួល ទាល់តែមានការព្រមព្រៀងគ្នា មួយវិញ ទៀតផ្ទះឈើបើមានការចាប់រំលោភ និងមានការរើបំរាស់ ប្រសិនបើមានការរើបំរាស់ គោះតែជើងបន្តិច ក៏ឮដល់ឪពុកម្តាយដែលសំរាន្តនៅក្រោមផ្ទះហើយ តែនេះគឺអត់មានទេ អត់មានស្នូរនៃការរើបំរាស់ទេ ហើយជនរងគ្រោះអះអាងថា កូនក្តីខ្លួនបានគំរាមសម្លាប់តែប៉ុណ្ណឹង ដូចនេះភស្តុតាងមិន គ្រប់គ្រាន់ក្នុង ការឲ្យតុលាការជឿនោះទេ។ ចំណុចមួយទៀតឃើញថាចម្លើយជនរងគ្រោះឆ្លើយប្រែប្រួល នៅនគរបាល យុត្តិធម៌គាត់បានឆ្លើយថា នៅយប់ថ្ងៃទី០៤ បន្ទាប់មកថ្ងៃទី០៥ ទី០៦ កូនក្តីខ្លួនចូលមក ក្នុងកន្លែង ដំណេកគាត់ ដល់នៅចៅក្រមស៊ើបសួរគាត់បានឆ្លើយថា ថ្ងៃមិនចាំវិញដែលបានរួមភេទ បន្ទាប់មក គាត់ឆ្លើយថា លើកទី២ នៅពីបីថ្ងៃក្រោយបានកូនក្តីខ្លួនឡើងមកម្តងទៀត លើកទី៣ គាត់ឆ្លើយថា មួយ អាទិត្យក្រោយកូនក្តីខ្លួនឡើងមកទៀត ចម្លើយមានការប្រែប្រួល។ ពិនិត្យលើចម្លើយ សាក្សីឈ្មោះ វ៉ែន ស្រីហុង ដែលបានទៅគេង ជាមួយជនរងគ្រោះគាត់បាន ឆ្លើយថា នៅពេលដែល គាត់កំពុងតែគេងលក់ ម៉ោងប្រហែល២៣ គាត់ភ្ញាក់ឡើង គាត់បានឃើញកូនក្តីខ្លួននៅពបពីលើ [redacted] ស្រីលៀប គាត់ក៏ស្ទុះ ងើបឡើង រឿងបែកដោយសារនាង [redacted] ស្រីហុង បានឃើញហើយក៏បែកការណ៍ ហើយក៏ស្ទុះឡើង ដើម្បីទៅប្រាប់ឪពុកម្តាយ និងនាំកូនក្តីខ្លួនទៅនគរបាល មិនជួបក៏នាំទៅប្រគល់ឲ្យ ឪពុកម្តាយកូនក្តីខ្លួន វិញ ដូចនេះជាការមួយត្រូវរ៉ូវគ្នា ហើយបើយោងតាមកោសល្យវិច័យបញ្ជាក់ថា ជនរងគ្រោះឈ្មោះ [redacted] ស្រីលៀប អាយុ១៥ឆ្នាំ គឺសន្ទះទ្វារមាសចំហតាំងពីយូរមកហើយ មិនមែនទើបតែចាប់រំលោភទេ គឺមាន ការធ្លាប់រួមភេទជាច្រើនដងមកហើយ មិនដឹងថាមានតែកូនក្តីខ្លួន ឬក៏អ្នកផ្សេងទេ។ បើយោងតាមសំបុត្រ កំណើតរបស់ [redacted] ស្រីលៀប គាត់កើតថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩២ អញ្ចឹងបើយើងដកក្បាលឆ្នាំ គឺគាត់ មានអាយុ១៧ឆ្នាំ គិតដល់ឆ្នាំ២០០៧ ថ្ងៃកើតហេតុ។ យោងតាមមាត្រា២៣៩ អនីតិជនដែលមានអាយុ ១៥ឆ្នាំឡើង មានសិទ្ធិក្នុងការរួមភេទ ដូចនេះឃើញថាក្នុង រឿងនេះ កូនក្តីខ្លួនគឺមិនបានចាប់រំលោភទេ គឺគាត់ទទួលស្គាល់ថា គាត់ពិតជាបានរួមភេទ, បើមិនមានហិង្សា មិនអាចចោទថាចាប់រំលោភទេ។ ក្នុង រឿងនេះឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការ ចោទប្រកាន់ កូនក្តីខ្លួន ពីបទ រំលោភសេពសន្ថវៈ

នោះទេ សុំលោកប្រធានក្រុមប្រឹក្សា និងចៅក្រមប្រឹក្សាមេត្តាពិចារណាលើភស្តុតាងទាំងអស់នេះ ហើយសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ,

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍

## យល់ឃើញថាៈ

១- បណ្តឹងទាស់លេខ ០៦ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] រឿន ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា៤១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- កាលពីថ្ងៃទី០៤, ០៥ និង០៦ ខែកុម្ភៈ ឆ្នាំ២០០៧ មានអំពើរំលោភសេពសន្ថវៈ បានកើតឡើង ដោយជនល្មើសឈ្មោះ [redacted] រឿន បានលបឡើងទៅលើផ្ទះជនរងគ្រោះ នៅវេលាម៉ោងប្រមាណ ១១យប់។ ការរំលោភសេពសន្ថវៈ នៅយប់ថ្ងៃទី០៤ និង០៥ បានសម្រេច, ឯនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៧ ត្រូវឪពុកជនរងគ្រោះ ចាប់យកទៅប្រគល់ទៅឲ្យអាជ្ញាធរសមត្ថកិច្ច តែមិនជួប ក៏យកទៅប្រគល់ឲ្យឪពុកម្តាយជនជាប់ចោទនៅយប់នោះតែម្តង។

៣- តាមចម្លើយជនជាប់ចោទ បានសារភាពថា ខ្លួនពិតជាបាន ឡើងទៅលើផ្ទះជនរងគ្រោះនៅក្នុងវេលាយប់ ថ្ងៃទី០៤, ០៥, ០៦ ខែកុម្ភៈ ឆ្នាំ២០០៧ មែន ប៉ុន្តែនៅយប់ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៧ មិនបានសម្រេចទេ ដោយឪពុកជនរងគ្រោះទាន់ ហើយចាប់ខ្លួនយកទៅប្រគល់ឲ្យអាជ្ញាធរ ឃុំ តែមិនជួបក៏យកខ្លួនទៅប្រគល់ឲ្យឪពុកម្តាយខ្លួន។ ខ្លួនទៅរួមភេទនេះ គឺដោយសារមានការព្រមព្រៀងរវាងខ្លួន និងជនរងគ្រោះឈ្មោះ [redacted] ស្រីលៀប និងបានហៅឲ្យខ្លួនទៅ ទើបមិនស្រែក។

៤- តាមចម្លើយជនរងគ្រោះនៅតុលាការថ្នាក់ក្រោមថា នៅយប់ថ្ងៃទី០៤, ០៥ ខែកុម្ភៈ ឆ្នាំ២០០៧ ជនជាប់ចោទ បានឡើងទៅរំលោភខ្លួន នៅលើផ្ទះពេលដែលខ្លួនកំពុងដេកលក់, បានសម្រេចទាំង ២យប់ នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៧ ជនជាប់ចោទឡើងទៅរំលោភខ្លួនទៀត តែឪពុកម្តាយខ្លួនដឹងក៏បានចាប់ជនជាប់ចោទ នាំទៅប្រគល់ឲ្យអាជ្ញាធរ តែមិនជួបក៏នាំឲ្យឪពុករបស់ជនជាប់ចោទ។

ខ្លួនមិនបានព្រមព្រៀងអ្វីជាមួយជនជាប់ចោទទេ ហើយក៏មិនបានស្រលាញ់ដែរ តែដោយខ្លួនខ្លាចស្លាប់ ទើបមិនហ៊ានស្រែក តែនៅយប់ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៧ ខ្លួនបានហៅបងប្អូនជីដូនមួយខ្លួន

ឲ្យទៅដេកជាមួយ ព្រោះខ្លាចជនជាប់ចោទឡើងទៅធ្វើបាន់ខ្លួនទៀត។

៥- មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅ ភូមិព្រៃកតាមេម ឃុំព្រៃកស្តី ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី០៤, ០៥, ០៦ ខែកុម្ភៈ ឆ្នាំ២០០៧ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ប៉ុន្តែ ដោយអនុលោមតាមមាត្រា១០ នៃក្រមព្រហ្មទណ្ឌ គួរកែប្រែទៅជាបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅ ភូមិព្រៃកតាមេម ឃុំព្រៃកស្តី ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី០៤, ០៥, ០៦ ខែកុម្ភៈ ឆ្នាំ២០០៧ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា២៣៩ និង២៤១ នៃក្រមព្រហ្មទណ្ឌវិញ និងសម្រេចឡើងវិញ។

៦- ចំណុចទី២ នៃសាលដីកាព្រហ្មទណ្ឌលេខ ០៧ ក្រ.អ.ស ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ សម្រេចមានការខ្វះខាត គួរកែប្រែ និងសម្រេចឡើងវិញ ដូចយល់ឃើញខាងលើ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងទាស់លេខ០៦ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] រឿន ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ០៧ ក្រ.អ.ស ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែចំណុចទី២ ត្រូវ:

ក. កែប្រែបទចោទលើជនជាប់ចោទ ពីបទ រំលោភសេពសន្ថវៈ ដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ទៅជាបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិព្រៃកតាមេម ឃុំព្រៃកស្តី ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី ០៤, ០៥, ០៦ ខែកុម្ភៈ ឆ្នាំ២០០៧ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ២៣៩, មាត្រា ២៤១ និងមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ វិញ។

ខ. ផ្តន្ទាទោសឈ្មោះ [redacted] រឿន ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៨ (ប្រាំបី) ឆ្នាំ គិតពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៨ ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិព្រៃកតាមេម ឃុំព្រៃកស្តី ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី ០៤, ០៥, ០៦ ខែកុម្ភៈ ឆ្នាំ២០០៧ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ២៣៩ និងមាត្រា១០ នៃក្រមព្រហ្មទណ្ឌ។

ក្រៅពីនេះទុកនៅដដែល។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី, បើកផ្លូវសាទុក្ខ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះទៅ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។** ៕

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

.......................................................................................................................

| | |
|---|---|
| បានឃើញ | ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម |
| ប្រធានសាលាឧទ្ធរណ៍ | ភ្នំពេញ, ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៥ |
| [redacted] | ក្រឡាបញ្ជី |
| | [redacted] |